**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** ......២៥២...... **ក.ប/ស.ជ.ណ.ម.ហ**

# សេចក្តីជូនដំណឹង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដល់ម្ចាស់ឬនាយកសហគ្រាស គ្រឹះស្ថាន និងជនបរទេសទាំងអស់ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិមាត្រា១ នៃច្បាប់ស្តីពីការងារ ឱ្យបានជ្រាបថា យោងមាត្រា២៦១ មាត្រា២៦៤ និងមាត្រា២៦៥ នៃច្បាប់ស្តីពីការងារ នៃព្រះរាជាណាចក្រកម្ពុជា និងប្រកាសលេខ១៩៦ ក.ប/ប្រ.ក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៤ស្តីពីការប្រើប្រាស់ហត្ថពលកម្មបរទេស ប្រកាសលេខ១៩៥ ក.ប/ប្រ.ក ស្តីពីបណ្ណការងារ និងសៀវភៅការងារជនបរទេស និងប្រកាសលេខ ៣៥២ ក.ប/ប្រ.ក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រង ទិន្នន័យកម្លាំងពលកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម សូមម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានទាំងឡាយដែលមានសេចក្តីត្រូវការប្រើប្រាស់ហត្ថពលកម្មបរទេស (កូតា) សម្រាប់ឆ្នាំ២០១៨ រៀបចំសំណើស្តីពីការប្រើប្រាស់ហត្ថពលកម្មបរទេស តាមរយៈគេហទំព័រ www.fwcms.mltv.gov.kh **ចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧។** ចំពោះម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានទាំងឡាយដែលមានប្រើប្រាស់ហត្ថពលកម្មបរទេស និងជនបរទេសដែលប្រកបមុខរបរណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញបែបបទធ្វើបណ្ណការងារ និងសៀវភៅការងារ និងពន្យារសុពលភាពបណ្ណការងារ និងសៀវភៅការងារជនបរទេសឆ្នាំ២០១៨ តាមរយៈគេហទំព័រ www.fwcms.mltv.gov.kh **ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៨។**

ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានទាំងឡាយ និងជនបរទេសដែលប្រកបមុខរបរណាមួយដែលមិនបានអនុវត្តត្រឹមត្រូវតាមសេចក្តីជូនដំណឹងនេះ ក្រសួងនឹងចាត់វិធានការ អនុវត្តការផាកពិន័យតាមទោសប្បញ្ញត្តិដែលមានចែងក្នុងជំពូកទី១៦ នៃច្បាប់ស្តីពីការងារ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងជនបរទេសទាំងអស់នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះដោយប្រសិទ្ធភាព។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១៧

រដ្ឋមន្ត្រី

**អ៊ិត សំហេង**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ក្រសួងមហាផ្ទៃ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  "ដើម្បីជូនជ្រាប"
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត
  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- សមាគមនិយោជក"ដើម្បីជ្រាប និងអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៥